សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

UNIVERSITE ROYALE DE DROIT ET DES SCIENCES ECONOMIQUES

ROYAL UNIVERSITY OF LAW AND ECONOMICS

# កិច្ចការស្រាវជ្រាវ

## មុខវិជ្ជា: វិធីសាស្ត្រស្រាវជ្រាវ

## ប្រធានបទ: ការបកស្រាយច្បាប់ព្រហ្មទណ្ឌ


**សមាជិកក្រុម:**

១. ជាង លីមស៊ាង

២. គង់ វង្សសុជាតិ

៣. ភាព កនិកា

៤. សុភឿន ឆេងលៀង

៥. ឡេង សុវណ្ណតារ៉ង

៦. ពុតសុធា ឧត្តម

៧. ផាន់ ឡាយហៀង

**សាស្ត្រាចារ្យណែនាំ: បណ្ឌិត ព្រុំ ធេវី**


ឆ្នាំសិក្សា:២០២៥-២០២៦

# អារម្ភកថា

ជាបឋមយើងខ្ញុំដែលជានិស្សិតបរិញ្ញាបត្រនីតិសាស្ត្រនៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចសូមគោលរពជម្រាបសួរអ្នកគ្រូ ព្រុំ ទេវី និងមិត្តអ្នកអានជាទីមេត្រី។ យើងខ្ញុំពិតជាមានសេចក្តីសប្បាយរីករាយយ៉ាងក្រៃលែងដែលបានទទួលនូវចំណេះដឹងដែលអ្នកគ្រូបានខិតខំយកចិត្តទុកដាក់ក្នុងការបង្ហាត់បង្រៀននូវមុខវិជ្ជា**កិច្ចការស្រាវជ្រាវ** មកដល់យើងខ្ញុំ។

ជាងនេះទៀត ក្នុងកំឡុងពេលសិក្សាអ្នកគ្រូក៏បានដាក់នូវ កិច្ចការស្រាវជ្រាវមកដល់រូបខ្ញុំដែលមានប្រធានបទការបកស្រាយច្បាប់ព្រហ្មទណ្ឌ ។ជាការពិតណាស់ប្រធានបទនេះពិតជាបានផ្តល់នូវចំណេះដឹងថ្មីៗនិង បទពិសោធជាច្រើនដែលទាក់ទងទៅនឹងការស្រាវជ្រាវនេះ។ អាស្រ័យហេតុនេះហើយយើងខ្ញុំមានសង្ឃឹម និង ជឿលដាក់យ៉ាងមុតមាំថាសំណៅខ្លឹមសារនេះនឹងក្លាយទៅជាគោលគំនិតមួយសម្រាប់អ្នកស្រាវជ្រាវក្រោយៗទៀត។យើងខ្ញុំក៏សូមអភ័យទោសទុកជាមុននូវរាល់កំហុសខុសឆ្គងដែលបានកើតឡើងដោយអចេតនានឹងទទួលបាននូវការកែលម្អបន្ថែមនូវចំនុចខ្វះខាត់ពីលោកគ្រូសាស្ត្រចារ្យ និងមិត្តអ្នកអានទាំងអស់គ្នា។

ទីបញ្ចប់យោងខ្ញុំសូមគោរពជូនដល់អ្នកគ្រូ **ព្រុំ ទេវី** និងមិត្តអ្នកអានទាំងជា អស់គ្នាជួបតែសេចក្តីចម្រើនសុខភាពល្អបរិបូណ៍និងសំណាងល្អគ្រប់ពេលវេលា។

# សេចក្ដីថ្លែងអំណរគុណ

យើងខ្ញុំជាក្រុមទីដប់ ដែលជានិស្សិតថ្នាក់បរិញ្ញាប័ត្រផ្នែក នីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមលំឱនកាយគោរពនិងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ៖

លោកឪពុក អ្នកម្ដាយ ដែលបានចិញ្ចឹមបីបាច់ថែរក្សា និងផ្ដល់នូវសេចក្ដីស្រឡាញ់មេត្តាករុណា អប់រំទូន្មានកូនអោយមានសេចក្ដីព្យាយាមអំណត់ក្លាហាន ព្រមទាំងបានធ្វើពលិកម្មគ្រប់យ៉ាងដល់កូនរហូតបានបញ្ចប់ ការសិក្សាដោយទទួលបាននូវចំណេះដឹងថ្លៃថ្លារហូតដល់ចប់ចុងចប់ដើម។ កូនសូមក្រាបប្រណិបត្តិ និងសំដែងក តញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុតចំពោះអ្នកមានគុណទាំងពីរដែលមានចំពោះកូនដែលមិនអាចកាត់ថ្លៃបាន។

ថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្ដមសាកលវិទ្យាធិការ លោកសាកលវិទ្យាធិការរង លោក-លោកស្រីប្រធានដេប៉ាតេម៉ង់ លោក-លោកស្រីប្រធានការិយាល័យ លោក-លោកស្រីអនុប្រធានដេប៉ាតាម៉ង់ លោក-លោកស្រីសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងបុគ្គលិកទាំងអស់ រួមទាំងផ្នែកសន្តិសុខ និងអ្នកអនាម័យ ដែលបានខិតខំប្រឹងប្រែងយកអស់ពីសមត្ថភាពទាំងកម្លាំងកាយ កម្លាំងចិត្ត និងកម្លាំងប្រាជ្ញាក្នុងការសរសេររបាយការណ៍បញ្ចប់ការសិក្សានេះកាន់តែទទួលបានលទ្ធផលល្អថែមទៀត។

ជាពិសេស យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះអ្នកគ្រូ **ព្រុំ ទេវី** ដែលបានដឹកនាំក្រុមយើងខ្ញុំដោយផ្ដល់នូវវិធីសាស្ត្រក្នុងការចុះសិក្សាស្រាវជ្រាវ និងប្រមូលព័ត៌មានយកមកចង ក្រងទើបសរសេរបានជារបាយការណ៍កម្មសិក្សាមួយច្បាប់នេះ។

# មាតិកា

ការបកស្រាយច្បាប់ព្រហ្មទណ្ឌ
សេចក្តីផ្តើម ........ 1
១. ការបកស្រាយច្បាប់ព្រហ្មទណ្ឌយ៉ាងតឹងរ៉ឹង ........ 2
២.វិធីសាស្រ្តក្នុងការបកស្រាយច្បាប់ ........ 4
២.១ ការបកស្រាយតាមអក្សរសាស្រ្ត ........ 4
២.៣ ការបកស្រាយតាមសទិសភាព ........ 6
៣ អត្ថបទបំភ្លឺច្បាប់ ........ 7
៤ អនុលោមច្បាប់ទៅតាមស្ថានភាពជាក់ស្តែង ........ 8
សេចក្តីសន្និដ្ឋាន ........ 9
ឯកសារយោង ........ 10

# សេចក្ដីផ្ដើម

ច្បាប់គឺជាវិធានសម្រាប់គ្រប់គ្រងទំនាក់ទំនងក្នុងសង្គម សំដៅជានានូវសណ្ដាប់ធ្នាប់ សាធារណៈ និងស្វែងរកនូវឧត្តមគតិនៃយុត្តិធម៌។ ជាទូទៅ ច្បាប់មានលក្ខណៈទូទៅ អរូបីយ និង ចាប់បង្ខំឱ្យបុគ្គលគ្រប់រូបនៅក្នុងសង្គមត្រូវតែប្រតិបត្តិតាម។ វិធានច្បាប់ត្រូវវិវត្តទៅតាមការវិវត្ត របស់សង្គម ដើម្បីអាចបន្តគ្រប់គ្រងទំនាក់ទំនងនៅក្នុងសង្គមបានល្អ។ ជាគោលការណ៍ ច្បាប់ មានអានុភាពអនុវត្តតែចំពោះស្ថានភាពដែលនឹងកើតមាននាពេលអនាគតបន្ទាប់ពីច្បាប់នេះបាន ចូលជាធរមាន (អានុភាពមិនប្រតិសកម្មនៃច្បាប់)។ ភាពច្បាស់លាស់ និងភាពគ្រប់ជ្រុងជ្រោយនៃ វិធានច្បាប់ អាស្រ័យទៅលើកម្រិតនៃការសិក្សាអង្កេត និងការវិភាគនៅក្នុងដំណើរការនៃការ បង្កើតវិធានច្បាប់ និងអាស្រ័យទៅលើការវិវត្តរបស់សង្គមផងដែរ ដែលមិនអាចត្រូវបានកំណត់ ទុកមុនបានយ៉ាងច្បាស់លាស់ទាំងស្រុងនោះទេ។ ក្នុងបច្ចេកទេសនីតិកម្ម អ្នកតាក់តែងច្បាប់អាច រៀបចំនូវបទប្បញ្ញត្តិច្បាប់ដែលមានអត្ថន័យទូលាយអាចបកស្រាយបានច្រើនបែបទៅតាម ស្ថានភាពសេដ្ឋកិច្ច-សង្គមដែលមានការវិវត្តជាប្រចាំ ដើម្បីចៀសវាងភាពមិនគ្រប់ជ្រុងជ្រោយរបស់ច្បាប់។ ប៉ុន្តែ ជាក់ស្តែង ដោយសារការវិវត្តយ៉ាងលឿនរបស់សង្គម និងបច្ចេកវិទ្យា វិធាន ច្បាប់មួយដែលសមស្របនៅក្នុងដំណាក់កាល ឬសម័យកាលមួយ អាចប្រែទៅជាមានភាព មិនសមស្របទៅវិញនាពេលអនាគត។ ទន្ទឹមនេះ វិធានច្បាប់ផ្សេងៗក៏អាចមិនមានសង្គតិភាព នឹងគ្នាទាំងស្រុងនោះដែរ។ ក្នុងន័យនេះ មិនមានច្បាប់ណាដែលមានភាពល្អឥតខ្ចោះ និង ច្បាស់លាស់គ្រប់ជ្រុងជ្រោយទាំងស្រុងនោះទេ។ ភាពមិនច្បាស់លាស់ ឬភាពខ្វះចន្លោះ ឬភាព មិនគ្រប់ជ្រុងជ្រោយនៃវិធានច្បាប់ គឺជាសារជាតិផ្ទាល់របស់ច្បាប់ ហើយតែងត្រូវបានទទួល ស្គាល់ដោយនីតិករផងដែរ។ ជាក់ស្តែង កថាខណ្ឌទី ២ នៃមាត្រា ៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជម្រះក្តីនៃរដ្ឋកម្ពុជាឆ្នាំ ១៩៩៣ ចែងថា "ក្នុងរឿងរដ្ឋប្បវេណី បើច្បាប់ ចែងមិនច្បាស់ ឬច្បាប់មិនបានចែង ត្រូវជំនុំជម្រះដោយផ្អែកទៅតាមទំនៀមទម្លាប់ប្រពៃណី វិចារណញ្ញាណ ឬសមធម៌"។ ការណ៍នេះទាមទារឱ្យមានការបកស្រាយច្បាប់ និងការទាញហេតុផល គតិយុត្តដ៏សមស្រប និងសមហេតុផលមួយនៅក្នុងការអនុវត្តជាក់ស្តែង។

ក្នុងប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ ការបកស្រាយច្បាប់បានក្លាយជាប្រធានបទពិភាក្សា ដ៏ផុសផុលមួយនៅក្នុងទ្រឹស្តីនៃនីតិ ហើយកិច្ចពិភាក្សានេះធ្វើឡើងក្នុងគោលបំណងកំណត់ឱ្យបាននូវវិធីសាស្ត្របច្ចេកទេស ក៏ដូចជាវិធាននៃការបកស្រាយច្បាប់។ តើអ្វីទៅជាការបកស្រាយ ច្បាប់? តើនរណាខ្លះជាអ្នកមានសិទ្ធិក្នុងការបកស្រាយច្បាប់ ហើយតើការបកស្រាយនេះមាន អានុភាពចាប់បង្ខំសម្រាប់ការអនុវត្តដែរឬទេ? តើវិធីសាស្ត្របកស្រាយច្បាប់មានអ្វីខ្លះ? និង តើ ការបកស្រាយច្បាប់ត្រូវគោរពតាមវិធាន ឬគោលការណ៍អ្វីខ្លះ?

## ១. ការបកស្រាយច្បាប់ព្រហ្មទណ្ឌយ៉ាងតឹងរ៉ឹង

ក្នុងការអនុវត្តច្បាប់ព្រហ្មទណ្ឌ ចៅក្រមមានករណីយកិច្ចត្រូវតែធ្វើការបកស្រាយច្បាប់ព្រហ្មទណ្ឌយ៉ាងតឹងរ៉ឹង ។ ការបកស្រាយច្បាប់ គឺជាការស្វែង ប្រាកដរបស់ច្បាប់ ដើម្បីអាចអនុវត្តច្បាប់ឱ្យបានច្បាស់លាស់និង រកអត្ថន័យពិត បាន ត្រឹមត្រូវ ។

ជុំវិញបញ្ហាបកស្រាយច្បាប់ រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា នៅត្រង់ ៣៦ ថ្មី បានចែងថា ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចធានាការពារការ មាត្រា ១៣៦ ធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និង ច្បាប់ដែលរដ្ឋសភាបានអនុម័ត និង គោរពរដ្ឋធម្ម ព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ ។ យោងតាមបញ្ញត្តិខាងលើ ក្រុមប្រឹក្សា ធម្មនុញ្ញជាអ្នកបកស្រាយច្បាប់ រួមបញ្ចូលទាំងច្បាប់ព្រហ្មទណ្ឌផង ។ ជាការពិត មានណាស់ថា ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចបកស្រាយច្បាប់ នេះជាប្រការដែល នៃអាចប្រកែកបានទេ ប៉ុន្តែទន្ទឹមនឹងនេះ តុលាការក៏មានសមត្ថកិច្ចបកស្រាយ ច្បាប់ព្រហ្មទណ្ឌផងដែរ ក្នុងន័យយកច្បាប់មកអនុវត្តលើរឿងក្តីណាមួយដែល តុលាការកំពុងតែពិនិត្យដោះស្រាយ ។ ពេលខ្លះ ដើម្បីអាចដោះស្រាយវិវាទណា ចៅក្រមចាំបាច់ត្រូវតែធ្វើការបកស្រាយច្បាប់ព្រហ្មទណ្ឌ ។ ក្នុងករណី ដូចនេះ ចៅក្រមពុំបានរំលោភបំពានលើសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញទេ មួយបាន ។ ការបកស្រាយច្បាប់ដោយក្រុមប្រឹក្សាធម្មនុញ្ញធ្វើឡើងតាមការស្នើសុំជាក់លាក់ ក្រៅក្របខ័ណ្ឌវិវាទ ហើយតុលាការគ្រប់ជាន់ថ្នាក់ជាច់ខាតត្រូវតែគោរពតាម ។ ចំណែកឯការបកស្រាយច្បាប់ដោយតុលាការវិញមានគោលដៅតែមួយគត់ យ៉ាងណាអនុញ្ញាតឱ្យចៅក្រមអាចដោះស្រាយវិវាទបានតែប៉ុណ្ណោះ ។ មាត្រា ៥ នៃក្រមព្រហ្មទណ្ឌបានចែងបញ្ជាក់យ៉ាងច្បាស់អំពីលទ្ធភាពនៃ ការបកស្រាយច្បាប់ព្រហ្មទណ្ឌដោយចៅក្រម ។ បញ្ញត្តិនេះមានខ្លឹមសារដូចតទៅ ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់ត្រូវបកស្រាយយ៉ាងតឹងរ៉ឹង ។ ចៅក្រមមិនអាចពង្រីក សាលភាពអនុវត្ត ឬប្រព្រឹត្តតាមសទិសភាព (ភាពដូចគ្នា ឬស្រដៀងគ្នា) បានឡើយ ។

---

ក្រមព្រហ្មទណ្ឌ(ទសរកម១១០៩|០២២ ចុះថ្ងៃទី៣០ វិច្ឆិកា ២០០៩)

ក្រមព្រហ្មទណ្ឌ មាត្រា ៥ ការបកស្រាយច្បាប់ព្រហ្មទណ្ឌ

ការបកស្រាយច្បាប់តាមសទិសភាព គឺជាការបកស្រាយដោយពន្លាត ដំណោះស្រាយសម្រាប់ករណីប្រហាក់ប្រហែលណាមួយ ទៅលើករណីមួយផ្សេង ទៀតដែលមិនមានចែងក្នុងច្បាប់ ដោយយោងទៅលើមូលហេតុថា ក្នុងសម្មតិកម្ម ទាំងពីរនោះ គឺមានហេតុផលដូចគ្នា ដើម្បីឈានទៅដល់ដំណោះស្រាយដូចគ្នា។ ជាក់ស្តែង នៅក្នុងរឿងរដ្ឋប្បវេណី គេសង្កេតឃើញថា មានករណីខ្លះ ដែលត្រូវ បានតុលាការប្រើប្រាស់វិធីសាស្ត្រសទិសភាព ដើម្បីទទួលបានដំណោះស្រាយនៃ រឿងក្តី ដូចជា បទប្បញ្ញត្តិនៃមាត្រា ៩៨០ នៃក្រមរដ្ឋប្បវេណីទាក់ទងនឹងការបែង ចែកទ្រព្យសម្បត្តិរួមរវាងសហព័ទ្ធ អាចត្រូវបានតុលាការយកមកប្រើប្រាស់ ដើម្បី ដោះស្រាយវិវាទពាក់ព័ន្ធនឹងការបែងចែកទ្រព្យសម្បត្តិ ដែលអនីតិសង្វាសជន៉។ធ្វើ លទ្ធកម្ម (ទទួលបាន) ក្នុងពេលដែលរួមរស់នៅជាមួយគ្នាដូចជាប្តីប្រពន្ធ ។ ផ្ទុយទៅវិញ ក្នុងរឿងព្រហ្មទណ្ឌ នៅពេលដែលតុលាការអនុវត្តភារកិច្ច បកស្រាយច្បាប់ដើម្បីដោះស្រាយវិវាទណាមួយ តុលាការដាច់ខាតត្រូវតែគោរព តាមគោលការណ៍នីត្យានុកូលភាព ដោយត្រូវបកស្រាយច្បាប់យ៉ាងតឹងរ៉ឹងបាន សេចក្តីថា ចៅក្រមពុំមានសិទ្ធិបកស្រាយតាមសទិសភាព ឬ ពន្លាតដែនអនុវត្តនៃ ច្បាប់ព្រហ្មទណ្ឌ ទៅលើស្ថានភាពទាំងឡាយណាដែលជាជាក់ស្តែងច្បាប់ពុំបាន ចែងសំដៅដល់ឡើយ ។ ក៏ប៉ុន្តែ គោលការណ៍នេះមិនគប្បីអនុវត្តឡើយចំពោះ ច្បាប់ដែលមានភាពអនុគ្រោះដល់ជនជាប់ចោទ ដូចជាវិធាននៃយុត្តិកម្ម ជាដើម។

ឧទាហរណ៍ ៖

អំពើបន្លំ គឺជាបទល្មើសព្រហ្មទណ្ឌដែលមានចែងនៅមាត្រា ៣៨៤ នៃ ក្រមព្រហ្មទណ្ឌ ។ យោងតាមបទប្បញ្ញត្តិនេះ គឺជាបទបន្លំ អំពើរបស់បុគ្គលដែល ដឹងខ្លួនថាគ្មានលទ្ធភាពដាច់ខាតនឹងបង់ថ្លៃ ឬ ដែលសម្រេចចិត្តមិនបង់ថ្លៃ៖

១-ឱ្យគេបម្រើម្ហូបអាហារ ឬភេសជ្ជៈនៅក្នុងវង្គសាល ភោជនីយដ្ឋានឬ នៅ ក្នុងគ្រឹះស្ថានដទៃទៀតដែលបើកចំហដល់ សាធារណជន ។

---

ក្រមរដ្ឋប្បវេណី (នស|រកម|១២០៧|០៣០ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧)

ក្រមរដ្ឋប្បវេណី មាត្រា៩៨០ ការបែងចែកទ្រព្យសម្បិត្ត

២-ឱ្យគេប្រគល់បន្ទប់មួយ និង កាន់កាប់បន្ទប់នេះនៅក្នុងសណ្ឋាគារ ឬ គ្រឹះស្ថានដទៃទៀតដែលបើកចំហដល់សាធារណជន ។

៣-ឱ្យគេដឹកជញ្ជូនខ្លួនតាមត្រីចក្រយាន តាមរថយន្តឈ្នួល ឬ តាម មធ្យោបាយដឹកជញ្ជូនផ្សេងទៀត ។

ហេតុដូច្នេះ តុលាការមិនអាចបកស្រាយតាមសទិសភាព ដោយចាត់ទុក ថាជាអំពើបន្លំដែរ នូវអំពើរបស់បុគ្គលណាម្នាក់ដែលបានចូលហាងបម្រើសេវា អ៊ិនធើណែត ដោយដឹងខ្លួនថាគ្មានលទ្ធភាពដាច់ខាតនឹងបង់ថ្លៃប្រើប្រាស់ ពីព្រោះ ថា មាត្រា ៣៨៤ នៃក្រមព្រហ្មទណ្ឌមិនបានចែងដល់ស្ថានភាពនៃការមិនបង់ថ្លៃសេវាអ៊ិនធើណែតឡើយ។

## ២.វិធីសាស្ត្រក្នុងការបកស្រាយច្បាប់

ក្នុងការបកស្រាយច្បាប់ជាទូទៅ ចៅក្រមប្រើប្រាស់វិធីសាស្ត្របីយ៉ាង ៖

-ការបកស្រាយតាមអក្សរសាស្ត្រ: ការបកស្រាយដោយផ្អែកទៅលើ ពាក្យពេចន៍ ឃ្លាឃ្លោងរបស់ច្បាប់ ។

-ការបកស្រាយតាមប្រវត្តិនៃការធ្វើច្បាប់: ការបកស្រាយដោយផ្អែក លើអ្វីដែលត្រូវបានជជែកវែកញែកក្នុងពេលធ្វើច្បាប់ ដើម្បីឱ្យបាន ដឹងពីឆន្ទៈពិតប្រាកដរបស់អ្នកនីតិបញ្ញត្តិ ។

-ការបកស្រាយតាមសទិសភាព: ការបកស្រាយដោយប្រើវិធីប្រៀប ធៀប ឬតាមន័យដូច ។

### ២.១ ការបកស្រាយតាមអក្សរសាស្ត្រ

នៅក្នុងការតាក់តែងច្បាប់ ពាក្យពេចន៍នីមួយៗត្រូវបានជ្រើសរើសដោយផ្ចិតផ្ចង់។ ពាក្យ ពេចន៍ទាំងនេះ គឺជាឧបករណ៍ដែលនីតិករប្រើដើម្បីបង្ហាញពីវិធានច្បាប់ដែលនឹងត្រូវកំណត់។ ការប្រើប្រាស់ពាក្យនីមួយៗ មិនមែនជារឿងចៃដន្យនោះទេ។ ហេតុនេះ ការបកស្រាយច្បាប់ត្រូវ ផ្តើមចេញពីការពិនិត្យទៅលើពាក្យពេចន៍ និងឃ្លាប្រយោគនៃអត្ថបទច្បាប់ផ្ទាល់តែម្តង។ ពាក្យ ពេចន៍នៅក្នុងច្បាប់ អាចជា ពាក្យធម្មតា ពាក្យច្បាប់ និងជាពាក្យបច្ចេកទេស។ ជាគោលការណ៍ ច្បាប់បង្កើតឡើងសម្រាប់មនុស្សទូទៅ។

ក្នុងន័យដើម យុត្តិសាស្ត្រគឺជាវិទ្យាសាស្ត្រនៃនីតិ។ យុត្តិសាស្ត្រ សំដៅទៅលើដំណោះស្រាយទាំងឡាយដែលអ្នកច្បាប់ សម័យបុរាណបង្កើតឡើងនៅក្នុងការអនុវត្តការងាររបស់ខ្លួន។ បច្ចុប្បន្ន ពាក្យយុត្តិសាស្ត្រមានអត្ថន័យច្រើនបែបយ៉ាង។ ក្នុងន័យទូលាយ យុត្តិសាស្ត្រ គឺជាបណ្តាសេចក្តីសម្រេចទាំងឡាយរបស់តុលាការ។ ក្នុងន័យចង្អៀត យុត្តិសាស្ត្រសំដៅ លើសេចក្តីសម្រេចផ្សេងៗជាច្រើនរបស់តុលាការដែលបានសម្រេច ដោយមានលក្ខណៈស៊ីសង្វាក់គ្នាគ្រប់គ្រាន់ លើបញ្ហាច្បាប់ណាមួយដូចគ្នា"។ សូមអានលម្អិតអំពីយុត្តិសាស្ត្រនៅក្នុងសៀវភៅ "សេចក្តីផ្តើមនៃនីតិកម្ពុជា", PUC, រោងពុម្ព Funan, ២០០៥, ទំព័រ ៨៩-៩៣។

"សេចក្តីផ្តើមនៃនីតិកម្ពុជា", PUC, រោងពុម្ព Funan, ២០០៥, ទំព័រ.២៦, ទំព័រ ៨៩-៩៣។

ក្នុងន័យនេះ ក្រៅពីសញ្ញាណគតិយុត្ត និងវាក្យសព្ទ គតិយុត្ត អ្នកបកស្រាយច្បាប់ ត្រូវបកស្រាយពាក្យ (អាច/ត្រូវតែ...) អាយតនិបាត (នឹង/និង/ឬ) គុណនាម ឬគុណកិរិយានីមួយៗ (ដោយច្បាស់, តាមទម្លាប់) ដែលមានក្នុងអត្ថបទច្បាប់ ទៅតាមខាងលើ។

ក្បួនវេយ្យាករណ៍អក្សរសាស្ត្រ។ លើសពីនេះ ក្នុងការអនុវត្តវិធីសាស្ត្រ នេះ យើងអាចសន្និដ្ឋានបានថា អត្ថបទច្បាប់អាចបង្ហាញយ៉ាងច្បាស់នូវផ្នត់គំនិតរបស់នីតិករ។ នៅក្នុង ប្រព័ន្ធ Civil Law ប្រសិនបើនីតិករបានប្រើប្រាស់ពាក្យច្បាស់ និងមានន័យច្បាស់លាស់ហើយ នោះថៅក្រមត្រូវអនុវត្តតាមខ្លឹមសារនោះ។ ដោយឡែក នៅក្នុងបណ្តាប្រទេសមួយចំនួននៃ ប្រព័ន្ធច្បាប់ Common Law ចៅក្រមអាចធ្វើការកែប្រែអត្ថន័យធម្មតានៃពាក្យ ដើម្បីចៀសវាង ភាពមិនច្បាស់លាស់ ឬភាពមិនសមហេតុផលដែលអាចសំដែងចេញមកយ៉ាងច្បាស់នៅក្នុង ការអនុវត្ត។ វិធាននៃការបកស្រាយនេះ ត្រូវបានគេឱ្យឈ្មោះថាជាវិធាន "Golden

ជាឧទាហរណ៍ កថាខណ្ឌទី១ នៃមាត្រា ៩ នៃច្បាប់ភូមិបាល ឆ្នាំ២០០១ ចែងថា "ក្រុមហ៊ុន ដែលបានចុះបញ្ជីនៅកម្ពុជា ហើយដែលមានភាគហ៊ុនចាប់ពី ៥១% ឡើងទៅកាន់កាប់ដោយ រូបវន្តបុគ្គលមានសញ្ជាតិខ្មែរ ឬនីតិបុគ្គលនៃច្បាប់កម្ពុជា អាចជាកម្មសិទ្ធិករនៃទ្រព្យជាដីបាន។ មានតែចំនួនភាគរយនៃប្រាក់ហ៊ុនដែលមានចែងក្នុងលក្ខន្តិកៈក្រុមហ៊ុនតែប៉ុណ្ណោះទេដែលទទួលយកជាការបាន។ រាល់ការព្រមព្រៀងដែលចុះហត្ថលេខាជាលក្ខណៈឯកជនរវាងអ្នកចូលហ៊ុន ទាំងឡាយដែលមានន័យផ្ទុយពីនេះ ត្រូវទុកជាមោឃៈ និងគ្មានអានុភាព"។ តើអ្វីទៅជានីតិបុគ្គល នៃច្បាប់កម្ពុជា? តើនីតិបុគ្គលនៃច្បាប់កម្ពុជាសុទ្ធតែជានីតិបុគ្គលដែលមានសញ្ជាតិខ្មែរ? តើនីតិ បុគ្គលនៃច្បាប់កម្ពុជាអាចជានីតិបុគ្គលបរទេសដែរឬទេ? ការបកស្រាយទៅតាមពាក្យពេចន៍នៃ មាត្រា ៩ នេះ បានបើកចំហចំពោះរាល់នីតិបុគ្គលទាំងអស់ មិនថាជានីតិបុគ្គលដែលមាន គោលដៅស្វែងរកប្រាក់ចំណេញ ឬនីតិបុគ្គលដែលមិនស្វែងរកប្រាក់ចំណេញនោះទេ។ ប៉ុន្តែ ក្រុមហ៊ុនជានីតិបុគ្គលដែលមានគោលដៅស្វែងរកប្រាក់ចំណេញ។ ហេតុដូចនេះ ជាស្មារតីរបស់ច្បាប់ នីតិបុគ្គលនៃច្បាប់កម្ពុជានេះចង់សំដៅដល់តែនីតិបុគ្គលដែលស្វែងរកប្រាក់ចំណេញ ប៉ុណ្ណោះ។ ម្យ៉ាងទៀត យោងតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មឆ្នាំ២០០៥ បុត្រសម្ព័ន្ធរបស់ ក្រុមហ៊ុនបរទេស ជានីតិបុគ្គលដែលបង្កើតឡើងតាមច្បាប់នៃកម្ពុជា ប៉ុន្តែ ជានីតិបុគ្គលបរទេស។

---

ច្បាប់ភូមិបាល(នស|រកត|១១៩៨|៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨)

ច្បាប់ភូមិបាល មាត្រា ៩

ហេតុដូចនេះ យោងតាមស្មារតីរបស់ច្បាប់នៃមាត្រា ៩ នេះ "... កាន់កាប់ដោយរូបវន្តបុគ្គលមានសញ្ជាតិខ្មែរ ឬនីតិបុគ្គលនៃច្បាប់កម្ពុជា..."ជាស្មារតីរបស់នីតិករ គឺចង់សំដៅដល់តែនីតិបុគ្គលនៃ ច្បាប់កម្ពុជាដែលមានសញ្ជាតិខ្មែរ ដូចជារូបវន្តបុគ្គលតែប៉ុណ្ណោះ។

វិធីសាស្ត្របកស្រាយទៅតាមឆន្ទៈរបស់នីតិករ ត្រូវបានអ្នកច្បាប់មួយចំនួនរិះគន់ ដោយ បានលើកឡើងថា ភាពខ្វះចន្លោះជាសារជាតិផ្ទាល់របស់ច្បាប់។ មានន័យថា នីតិករមិនអាចចែង បានគ្រប់ជ្រុងទាំងអស់បាននោះទេ។ ហេតុដូចនេះ ការព្យាយាមស្វែងរកឆន្ទៈរបស់នីតិករនៅ ក្នុងវិស័យដែលគាត់មិនបានប្រមើលទុក ជារឿងដែលមិនសមហេតុផល។ លើសពីនេះ វាជារឿង ដ៏លំបាកក្នុងការស្វែងរកនូវឆន្ទៈពិតប្រាកដ ដែលជាឆន្ទៈរួមរបស់នីតិករណាស់ ដោយសារ សមាជិកទាំងអស់នៃអង្គនីតិប្បញ្ញត្តិដែលចូលរួមធ្វើការអនុម័តច្បាប់មានច្រើននាក់។ វាក៏ជារឿង ដែលមិនអាចជឿជាក់បានដែរថា សមាជិកទាំងអស់នៃអង្គនីតិបញ្ញត្តិមានឆន្ទៈ និងគំនិតដូចគ្នានៅ ពេលអនុម័តច្បាប់។

## ២.៣ ការបកស្រាយតាមសទិសភាព

សម្រាប់ការបកស្រាយតាមបែបសទិសភាព, ជាវិធីសាស្ត្របកស្រាយ ដើម្បីពង្រីកវិសាលភាពនៃវិធានច្បាប់។ កាលភាពនេះ សទិសភាព មានន័យថាភាពត្រូវគ្នា ឬភាពស្រដៀងគ្នា។ ក្នុងវិធីសាស្ត្រនេះ ការបកស្រាយច្បាប់ធ្វើឡើងដើម្បីយកវិធានគតិយុត្តដែលច្បាប់បានកំណត់ ចំពោះករណីជាក់លាក់មួយ ទៅអនុវត្តដូចគ្នាចំពោះករណីមួយផ្សេងទៀតដែលច្បាប់មិនបានចែង ឱ្យបានច្បាស់ ប៉ុន្តែ មានលក្ខណៈស្រដៀងគ្នា ឬត្រូវគ្នានឹងករណីដែលច្បាប់បានកំណត់។ ការបក ស្រាយច្បាប់តាមបែបសទិសភាពនេះ អនុញ្ញាតឱ្យចៅក្រមអាចបំពេញបន្ថែមនូវភាពខ្វះចន្លោះ របស់ច្បាប់ ដើម្បីទទួលបាននូវដំណោះស្រាយមួយប្រកបដោយសមធម៌។ សមធម៌នេះគឺជា មូលដ្ឋានដ៏រឹងមាំសម្រាប់ការបកស្រាយច្បាប់តាមបែបសទិសភាព។ ការបកស្រាយតាមបែបសទិសភាពនេះ ត្រូវបានប្រើជាញឹកញាប់ ប៉ុន្តែក្នុងករណីខ្លះ ច្បាប់ហាមមិនឱ្យមានការបកស្រាយ តាមបែបសទិសភាពនេះទេ។ ជាក់ស្តែង ក្រមព្រហ្មទណ្ឌ បានកំណត់យ៉ាងច្បាស់នៅក្នុងមាត្រា ៥ ថា "ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់ត្រូវបកស្រាយយ៉ាងតឹងរ៉ឹង។...ចៅក្រមមិនអាចពង្រីកវិសាលភាពអនុវត្ត ឬប្រព្រឹត្តតាមសទិសភាពបានឡើយ"។ គោលការណ៍នៃការបកស្រាយយ៉ាងតឹងរ៉ឹងនូវបទប្បញ្ញត្តិ ព្រហ្មទណ្ឌ គឺជាលទ្ធផលនៃគោលការណ៍នីត្យានុកូលភាពនៃបទល្មើស និងគោលការណ៍នីត្យានុកូល ភាពនៃទោស ដែលមានចែងក្នុងមាត្រា ៣ នៃក្រមព្រហ្មទណ្ឌ ដែលចែងថា "មានតែអំពើដែល បង្កើតជាបទល្មើសនៅពេលដែលអំពើនោះមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមាន

ប៉ុណ្ណោះ ទើបត្រូវផ្តន្ទាទោសព្រហ្មទណ្ឌបាន។ មានតែទោសដែលមានចែងក្នុងបទប្បញ្ញត្តិ ព្រហ្មទណ្ឌជាធរមាននៅពេលដែលបទល្មើសត្រូវបានប្រព្រឹត្តប៉ុណ្ណោះ ទើបអាចត្រូវប្រកាសបាន"។

## ៣ អត្ថបទបំភ្លឺច្បាប់

នៅចំពោះមុខអត្ថបទច្បាប់ព្រហ្មទណ្ឌដែលមិនសូវច្បាស់លាស់ ឬក៏មាន អត្ថន័យគួរឱ្យមន្ទិលសង្ស័យ ថៅក្រមត្រូវខិតខំប្រឹងប្រែងរកឱ្យឃើញនូវអត្ថន័យ យ៉ាងពិតប្រាកដរបស់ច្បាប់ ដោយពិនិត្យឡើងវិញនូវស្មារតីពិតប្រាកដរបស់អ្នក នីតិបញ្ញត្តិ តាមរយៈការពិចារណាលើការពិភាក្សារបស់អ្នកនីតិបញ្ញត្តិក្នុងពេល រៀបចំតាក់តែង និងអនុម័តច្បាប់នោះ (បកស្រាយតាមប្រវត្តិនៃការធ្វើច្បាប់) ឬ ដោយធ្វើការវិភាគលើអត្ថន័យច្បាប់តាមលក្ខណៈសមស្រប និង ប្រកបដោយ វិចារណញ្ញាណ ។ ល្គឹកណានៅតែមានភាពមិនច្បាស់លាស់ក្តី ឬនៅតែមានភាព មន្ទិលសង្ស័យក្តី ថៅក្រមត្រូវតែគោរពតាមបទប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញត្រង់មាត្រា ៣៨ កថាខណ្ឌទី ៧ ដែលកំណត់ថា វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ ជនជាប់ចោទ ។ បញ្ញត្តិ "វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ អាចត្រូវបានយកមកអនុវត្ត ក្នុងករណីចំនួនពីរយ៉ាងគឺ ៖

-ច្បាប់ដែលកំណត់អំពើណាមួយថាជាបទល្មើស តែមានភាពមិនច្បាស់ លាស់បង្កឱ្យមានមន្ទិលសង្ស័យ ។ នេះគឺជា ការមន្ទិលសង្ស័យលើច្បាប់ ។

-ភស្តុតាងដែលដាក់បន្ទុកលើជនជាប់ចោទ មិនបានបង្ហាញយ៉ាងច្បាស់ លាស់ថា ជនជាប់ចោទបានប្រព្រឹត្តបទល្មើសយ៉ាងពិតប្រាកដទេ ពោលគឺបង្កនូវ មន្ទិលសង្ស័យសម្រាប់ថៅក្រម ។ នេះគឺជា ការមន្ទិលសង្ស័យលើអង្គហេតុ ។

ជាទូទៅ ការបកស្រាយច្បាប់តឹងរ៉ឹងគឺសំដៅទៅលើការបកស្រាយតាម អក្សរសាស្ត្រ ។ ក៏ប៉ុន្តែក្នុងករណីមួយចំនួន ការបកស្រាយតឹងរ៉ឹងពុំមានន័យថា ដាច់ខាតត្រូវតែបកស្រាយតាមពាក្យពេចន៍របស់ច្បាប់មួយរយភាគរយទេ ។ នៅ ពេលខ្លះ ទោះបីជាពាក្យពេចន៍មានលក្ខណៈច្បាស់លាស់ក៏ដោយ ក៏ប៉ុន្តែពុំមែនជាគោលដៅរបស់អ្នកនីតិបញ្ញត្តិទេ ។

---

ក្រមព្រហ្មទណ្ឌ មាត្រា ៣

រដ្ឋធម្មនុញ្ញ ព្រះរាជក្រមប្រកាសឱ្យប្រើនៅថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៩៣

រដ្ឋធម្មនុញ្ញ មាត្រា ៣៨ កថាខណ្ឌទី ៧

## ៤ អនុលោមច្បាប់ទៅតាមស្ថានភាពជាក់ស្តែង

នៅពេលដែលច្បាប់ត្រូវបានតាក់តែង និងអនុម័តរួចហើយមក ជាទូទៅច្បាប់មានលក្ខណៈច្បាស់លាស់ ហើយជាធម្មតា គឺពុំទាមទារឱ្យមានការខិតខំធ្វើ ការបកស្រាយច្បាប់ពីសំណាក់ចៅក្រមឡើយ ។ ក៏ប៉ុន្តែបន្ទាប់ពីពេលវេលាយ៉ាង យូរបានកន្លងផុតទៅ សង្គមក៏បានវិវត្តទៅរកស្ថានភាពមួយដែលគេពុំអាចប៉ាន់ ស្មានដល់ នៅខណៈដែលច្បាប់ត្រូវបានបង្កើតឡើង ។ ដូច្នេះការលួចក្នុងសម័យ មុនសំដៅជាពិសេសទៅលើការចាប់យកទ្រព្យសម្បត្តិរបស់អ្នកដទៃ ដោយគ្មាន ការយល់ព្រមពីម្ចាស់ទ្រព្យ ។ លុះនៅពេលដែលសង្គមចេះតែវិវត្តទៅមុខ មនុស្សក៏ ចេះប្រើប្រាស់ភ្លើងអគ្គិសនី ហេតុដូច្នេះក៏ចោទជាសំណួរឡើងថា តើគេអាចលួច ភ្លើងអគ្គិសនីបានដែរឬទេ ? ចៅក្រមមានតួនាទីសម្របសម្រួលដោយអនុលោមច្បាប់ទៅតាមស្ថានភាពជាក់ស្តែងដែលបានកើតឡើង និង ធ្វើការបញ្ជាក់ថា តើ ភ្លើងអគ្គិសនីគឺជាទ្រព្យសម្បត្តិ ហើយអាចធ្វើជាកម្មវត្ថុនៃអំពើលួចបានដែរឬទេ ។ ចំពោះបញ្ហានេះ មាត្រា ៣៥៤ នៃក្រមព្រហ្មទណ្ឌបានចែងគូសបញ្ជាក់យ៉ាងច្បាស់ ថា ត្រូវចាត់ទុកជាអំពើលួច អំពើប្រើប្រាស់ដោយទុច្ចរិតនូវថាមពល ដែលនាំឱ្យ ខូចប្រយោជន៍របស់អ្នកដទៃ ។ ដូច្នេះការលួចថាមពលអគ្គិសនី គឺជាអំពើលួចដែលត្រូវផ្តន្ទាទោសតាមក្រមព្រហ្មទណ្ឌ ។

ហេតុនេះ ការបកស្រាយច្បាប់យ៉ាងតឹងរ៉ឹងពុំមែនមានន័យថា ច្បាប់ត្រូវ តែបកស្រាយដោយកំណត់នូវដែនអនុវត្តច្បាប់ តែត្រឹមលើស្ថានភាពទាំងឡាយ ណាដែលអ្នកនីតិបញ្ញត្តិនៅជំនាន់នោះអាចប៉ាន់ស្មានដល់ប៉ុណ្ណោះទេ ។

---

ក្រមព្រហ្មទណ្ឌ មាត្រា ៣៥៤ អំពើលួច អំពើប្រើប្រាស់ដោយទុច្ចរិតនូវ ថាមពល ដែលនាំឱ្យ ខូចប្រយោជន៍របស់អ្នកដទៃ

# សេចក្តីសន្និដ្ឋាន

ការបកស្រាយច្បាប់គឺជាកិច្ចការមួយដ៏មានសារៈសំខាន់ និង ត្រូវធ្វើឡើងដោយប្រុងប្រយ័ត្ន និង ត្រឹមត្រូវ ហើយជាពិសេស ចៅក្រមមិនអាច បំពានគោលការណ៍នៃការបកស្រាយច្បាប់ព្រហ្មទណ្ឌយ៉ាងតឹងរ៉ឹងនោះទេ ដោយ មូលហេតុថា ការបំពានគោលការណ៍នេះនឹងនាំទៅដល់ការរំលោភបំពានលើសិទ្ធិ និងសេរីភាពរបស់បុគ្គលដែលការពារដោយរដ្ឋធម្មនុញ្ញជាក់ជាមិនខាន ។

## ឯកសារយោង

១. អត្ថបទស្រាវជ្រាវ និង វិភាគ «ការបកស្រាយច្បាប់» រៀបរៀងដោយ**ឯកឧត្តម ញាន វណ្ណៈ** និង **ឯកឧត្តម សេងនាង**

២. និតិព្រហ្មទណ្ឌទូទៅ រៀបរៀងដោយ**លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ** និង **លោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត**